►トピック 家と職場

# 第8課 山田さんはどこにいますか？

これまで会社で働いたことがありますか？　会社には、どんな部屋や施設がありますか？
មកដល់ពេលនេះតើអ្នកធ្លាប់ធ្វើការក្រុមហ៊ុនដែរឬទេ? តើក្រុមហ៊ុននោះមានបន្ទប់និងអគារអ្វីខ្លះដែរ?

## 1. ここで打ち合わせをします

Can-do 31
職場の部屋を案内してもらいながら、簡単な説明を聞いて、何の部屋かがわかる。
អាចស្តាប់យល់ការពន្យល់ងាយៗពីបន្ទប់នីមួយៗពេលគេបង្ហាញបន្ទប់ក្នុងកន្លែងធ្វើការ។

### 1 ことばの準備
សិក្សាពាក្យ

【会社の部屋 បន្ទប់របស់ក្រុមហ៊ុន】

a. 更衣室



b. 食堂



c. 給湯室



d. 会議室



e. 喫煙所




f. 倉庫



（1）絵を見ながら聞きましょう。 08-01
ស្តាប់បណ្តើរ មើលរូបភាពបណ្តើរ។

（2）聞いて言いましょう。 08-01
ស្តាប់ហើយថាតាម។

（3）聞いて、a-f から選びましょう。 08-02
ស្តាប់រួចជ្រើសរើសពី a ដល់ f ។


©The Japan Foundation

## 2 会話(かいわ)を聞(き)きましょう。
ចូរស្តាប់ការសន្ទនា។

► はじめての職場(しょくば)で、部屋(へや)を案内(あんない)してもらっています。
អ្នកកំពុងត្រូវបានគេណែនាំបន្ទប់ផ្សេងៗ នៅកន្លែងធ្វើការដំបូងរបស់អ្នក។



**（1）何(なん)の部屋(へや)ですか。1 の a-f から選(えら)びましょう。**
តើបន្ទប់ទាំងនោះជាបន្ទប់អ្វីខ្លះ? ចូរជ្រើសរើសពី 1 a ដល់ f។

| ① 08-03 | ② 08-04 | ③ 08-05 | ④ 08-06 |
|---|---|---|---|
| | | | |

**（2）もういちど聞(き)きましょう。それぞれの部屋(へや)で、何(なに)をしますか。ア - エから選(えら)びましょう。**
ស្តាប់ការសន្ទនាម្តងទៀត។ តើបន្ទប់នីមួយៗត្រូវបានគេប្រើប្រាស់សម្រាប់ធ្វើអ្វីខ្លះ? ចូរជ្រើសរើសពី ア ដល់ エ។

ア. 着替(きが)えます



イ. ご飯(はん)を食(た)べます



ウ. お茶(ちゃ)をいれます



エ. 打(う)ち合(あ)わせをします



| ① 08-03 | ② 08-04 | ③ 08-05 | ④ 08-06 |
|---|---|---|---|
| | | | |

**（3）ことばを確認(かくにん)して、もういちど聞(き)きましょう。 08-03 ～ 08-06**
មើលពាក្យហើយស្តាប់ការសន្ទនាម្តងទៀត។

男性(だんせい) បុរស


©The Japan Foundation

## 形に注目

（１）音声を聞いて、＿＿＿＿＿にことばを書きましょう。 08-07
ស្តាប់ហើយបំពេញចន្លោះ។

ここは男性の更衣室です。ここ＿＿＿着替えます。
ここは給湯室です。ここ＿＿＿お茶をいれます。
ここは会議室です。ここ＿＿＿打ち合わせをします。
ここは食堂です。ここ＿＿＿ご飯を食べます。

「で」は、どんな意味だと思いますか。 ➡ 文法ノート❶
តើអ្នកគិតថា で មានអត្ថន័យដូចម្តេច?

（２）形に注目して、会話をもういちど聞きましょう。 08-03 ～ 08-06
ពិនិត្យមើលទម្រង់ហើយស្តាប់ការសន្ទនាម្តងទៀត។


©The Japan Foundation

## 2. 食堂(しょくどう)にいます

Can-do 32
人(ひと)の居場所(いばしょ)を質問(しつもん)したり、質問(しつもん)に答(こた)えたりすることができる。
អាចសួរនិងឆ្លើយសំណួរស្តីពីទីតាំងរបស់នរណាម្នាក់។

### 1 会話(かいわ)を聞(き)きましょう。
ចូរស្តាប់ការសន្ទនា។

► 職場(しょくば)で、人(ひと)を探(さが)しています。
ពួកគេកំពុងតែរកនរណាម្នាក់នៅកន្លែងធ្វើការ។

（1） ①-④の人(ひと)は、どこにいますか。
a-e から選(えら)びましょう。
わからないときは、「—」を書(か)きましょう。
តើមនុស្ស ① ដល់ ④ ពួកគេនៅឯណា? ចូរជ្រើសរើសពី a ដល់ e ហើយគូស ប្រសិនបើពួកគេមិនដឹង។




どこにいますか？
តើគាត់នៅឯណា?




| ① 山田(やまだ)さん 08-08 | ②永井(ながい)さん 08-09 | ③ 辻(つじ)さん 08-10 | ④ アマンダさん 08-11 |
|---|---|---|---|
| | | | |

（2） ことばを確認(かくにん)して、もういちど聞(き)きましょう。 08-08 ～ 08-11
មើលពាក្យហើយស្តាប់ការសន្ទនាម្តងទៀត។

たぶん ប្រហែល ｜ 探(さが)してみます ព្យាយាមរកមើល
～よ（いるよ） （相手(あいて)が知(し)らない情報(じょうほう)を教(おし)えるときに使(つか)う （ប្រើពេលប្រាប់ព័ត៌មានដែលដៃគូមិនដឹង））
～ね（いませんね） （相手(あいて)と情報(じょうほう)を共有(きょうゆう)するときに使(つか)う （ប្រើពេលចែករំលែកព័ត៌មានជាមួយដៃគូ））


©The Japan Foundation

## 形に注目

（１）音声を聞いて、＿＿＿＿＿にことばを書きましょう。 08-12
ស្តាប់ហើយបំពេញចន្លោះ។

A：山田さんは、＿＿＿＿＿＿＿＿に＿＿＿＿＿＿＿＿か？
B：食堂＿＿＿＿＿＿＿＿＿＿。

A：永井さんは、＿＿＿＿＿＿＿ですか？
B：会議室＿＿＿＿＿＿＿＿＿よ。

A：辻さんは、＿＿＿＿＿＿＿＿＿か？
B：＿＿＿＿＿＿＿＿＿＿ね。

A：アマンダさん、＿＿＿＿＿＿＿＿＿か？
B：＿＿＿＿＿＿＿＿＿＿＿＿ね。

! 人を探しているとき、どう質問していましたか。 ➡ 文法ノート❷
ពេលសួររកនរណាម្នាក់ តើគេប្រើសំនួនអ្វី?

! 人がどこにいるか、場所を教えるとき、どう言っていましたか。 ➡ 文法ノート❷
ពេលប្រាប់ពីទីកន្លែងដែលនរណាម្នាក់កំពុងមានវត្តមាន តើគេប្រើសំនួនអ្វី?

! 人がいないことを伝えるとき、どう言っていましたか。 ➡ 文法ノート❸
ពេលគេនិយាយថានរណាម្នាក់មិនមានវត្តមាននៅទីនោះ តើគេប្រើសំនួនអ្វី?

（２）形に注目して、会話をもういちど聞きましょう。 08-08 ～ 08-11
ពិនិត្យមើលទម្រង់ហើយស្តាប់ការសន្ទនាម្តងទៀត។


©The Japan Foundation

## 2 人がどこにいるか質問しましょう。
ចូរសួររកទីកន្លែងដែលនរណាម្នាក់កំពុងមានវត្តមាន។

①

すみません。山田さんは、どこにいますか？
すみません。山田さんは、どこですか？

食堂にいます。
食堂です。

わかりました。

②

すみません。辻さんは、いますか？

辻さんは、いませんね。
辻さんは、いないですね。

たぶん、倉庫です。

わかりました。

（1）会話を聞きましょう。 08-13 ／ 08-14
ចូរស្ដាប់ការសន្ទនា។

（2）シャドーイングしましょう。 08-13 ／ 08-14
ស្ដាប់ហើយថាតាមពីក្រោយឱ្យទាន់សំឡេង។

（3）1 のイラストを見て、練習しましょう。
ចូរអនុវត្តដោយមើលតាមរូបភាពដែលមាននៅក្នុង 1។

（4）自分がいる建物の中で人を探しているという設定で、ロールプレイをしましょう。
ចូរដើរតួរសន្ទនា។ អ្នកកំពុងរកនរណាម្នាក់នៅក្នុងអគារ។


©The Japan Foundation

# 3. はさみは、そこにあります

Can-do 33
職場などで、ものの置き場を質問したり、質問に答えたりすることができる。
អាចសួរ និងឆ្លើយសំណួរស្តីពីកន្លែងដាក់សម្ភារៈផ្សេងៗ នៅកន្លែងការងារ។

## 1 ことばの準備
សិក្សាពាក្យ

【位置 ទីតាំង】

a. 上



b. 下



c. 中



d. 横



（1）絵を見ながら聞きましょう。 08-15
ស្តាប់បណ្តើរ មើលរូបភាពបណ្តើរ។

（2）聞いて言いましょう。 08-15
ស្តាប់ហើយថាតាម។

（3）聞いて、a-d から選びましょう。 08-16
ស្តាប់ហើយជ្រើសរើសពី a ដល់ d។


©The Japan Foundation

## 2 会話を聞きましょう。
ចូរស្ដាប់ការសន្ទនា។

► 職場で、必要なものがどこにあるか、わかりません。近くの人に質問しています。
មនុស្សទាំងនេះកំពុងរករបស់ដែលគេត្រូវការតែគេមិនដឹងថាមាននៅឯណាទេ។ ពួកគេក៏សួរអ្នកដែលនៅក្បែរ។

（１） ①－⑤は、どこにありますか。イラストの中に★印を書き入れましょう。
តើ ① ដល់ ⑤ មាននៅឯណា? ចូរគូស ★ ពីលើរូបភាព។

① のり 08-17




□ ここ　□ そこ　□ あそこ

② ガムテープ 08-18




□ ここ　□ そこ　□ あそこ

③ FAX 08-19




□ ここ　□ そこ　□ あそこ

④ はさみ 08-20




□ ここ　□ そこ　□ あそこ


©The Japan Foundation

⑤ ごみ箱（ばこ） 08-21




☐ ここ　☐ そこ　☐ あそこ

（2）もういちど聞（き）きましょう。ものの場所（ばしょ）を教（おし）えるとき、教（おし）える人（ひと）は「ここ」「そこ」「あそこ」のどれを使（つか）っていましたか。☐にチェック ✔ をつけましょう。
ស្តាប់ការសន្ទនាម្តងទៀត។ ここ, そこ ឬ あそこ តើពាក្យមួយណាដែរគេបានប្រើពេលប្រាប់ពីទីកន្លែងរបស់វត្ថុក្នុងការសន្ទនា? ចូរគូស ✓ ក្នុងប្រអប់។

（3）ことばを確認（かくにん）して、もういちど聞（き）きましょう。 08-17 ～ 08-21
មើលពាក្យហើយស្តាប់ការសន្ទនាម្តងទៀត។

ありました វានៅទីនេះ។


©The Japan Foundation

## 形に注目

（１）音声を聞いて、＿＿＿＿にことばを書きましょう。 08-22 08-23
ស្តាប់ហើយបំពេញចន្លោះ។

A：のりは、＿＿＿＿＿にありますか？

B：＿＿＿＿＿です。

A：ガムテープは、どこですか？

B：＿＿＿＿＿です。

A：はさみ、ありますか？

B：＿＿＿＿＿にあります。

「ここ」「そこ」「あそこ」は、どう違うと思いますか。 2 （１）のイラストを見て、考えましょう。
➡ 文法ノート ❹
តើអ្នកគិតថាពាក្យ ここ,そこ និង あそこ ខុសគ្នាដូចម្តេច? ចូរគិតដោយមើលរូបភាពដែលមាននៅ 2 (1)។

引き出し＿＿＿中にあります。

コピー機＿＿＿横。

机＿＿＿上です。

机＿＿＿下。

ものの位置を説明するとき、どう言っていましたか。 ➡ 文法ノート ❺
ពេលគេនិយាយពីទីតាំងរបស់វត្ថុណាមួយ តើឃ្លាបែបណាដែលត្រូវបានគេប្រើនៅ

（２）形に注目して、会話をもういちど聞きましょう。 08-17 ～ 08-21
ពិនិត្យមើលទម្រង់ហើយស្តាប់ការសន្ទនាម្តងទៀត។


©The Japan Foundation

**3** ものがどこにあるか質問(しつもん)しましょう。
សួរសំនួរពីទីតាំងរបស់វត្ថុ។

すみません。**はさみ** は、どこにありますか？
すみません。**ガムテープ** は、どこですか？

**そこ** にあります。
**あそこ** です。

**机(つくえ)** の **上(うえ)** です。
**箱(はこ)** の **中(なか)** にあります。

ありがとうございます。

（１）会話(かいわ)を聞(き)きましょう。 08-24 08-25
ចូរស្ដាប់ការសន្ទនា។

（２）シャドーイングしましょう。 08-24 08-25
ស្ដាប់ហើយថាតាមពីក្រោយឱ្យទាន់សំឡេង។

（３）**2** のイラストを見(み)て、練習(れんしゅう)しましょう。
ចូរអនុវត្តដោយមើលរូបភាពក្នុង **2** ។

（４）教室(きょうしつ)にあるものを使(つか)って、どこにあるか質問(しつもん)しましょう。
ចូរសួរពីទីតាំងរបស់វត្ថុផ្សេងៗ ដែលមាននៅក្នុងថ្នាក់រៀនរបស់អ្នក។


©The Japan Foundation

## 4. 部屋の表示

can-do 34
**部屋の入り口の表示を見て、何の部屋かがわかる。**
អាចមើលយល់សញ្ញានៅមុខបន្ទប់ថាជាបន្ទប់អ្វី។

### 1 部屋の表示を見てみましょう。
ចូរមើលស្លាកសញ្ញាដែលមាននៅក្នុងបន្ទប់។

► 職場で、部屋の表示を見ています。
អ្នកកំពុងមើលស្លាកសញ្ញាក្នុងបន្ទប់នៅក្រុមហ៊ុនរបស់អ្នក។



**① - ⑥は何をする部屋ですか。**
តើ ①-⑥ ជាបន្ទប់សម្រាប់ធ្វើអ្វី?

①




②




 ©The Japan Foundation

③




④




⑤




⑥




**大切(たいせつ)なことば**

応接室(おうせつしつ) បន្ទប់ទទួលភ្ញៀវ ｜ 事務室(じむしつ) ការិយាល័យ

 ©The Japan Foundation

# 聴解(ちょうかい)スクリプト

## 1. ここで打(う)ち合(あ)わせをします

① 08-03

A：ここは男性(だんせい)の更衣室(こういしつ)です。ここで着替(きが)えます。

B：わかりました。

② 08-04

A：ここは給湯室(きゅうとうしつ)です。ここでお茶(ちゃ)をいれます。

B：はい。

③ 08-05

A：ここは会議室(かいぎしつ)です。ここで打(う)ち合(あ)わせをします。

B：はい。

④ 08-06

A：えっと、ここは食堂(しょくどう)です。ここでご飯(はん)を食(た)べます。

B：はい。

A：おいしいですよ。

## 2. 食堂(しょくどう)にいます

① 08-08

A：すみません。山田(やまだ)さんは、どこにいますか？

B：食堂(しょくどう)にいます。

A：わかりました。ありがとうございます。

② 08-09

A：あのう、すみません。永井(ながい)さんは、どこですか？

B：永井(ながい)さん？　ああ、会議室(かいぎしつ)にいるよ。

A：あ、どうも。


©The Japan Foundation

③ 08-10

A：すみません。辻(つじ)さんは、いますか？

B：辻(つじ)さんは……。あれ？　いませんね。たぶん、倉庫(そうこ)です。

A：じゃあ、探(さが)してみます。

④ 08-11

A：アマンダさん、いますか？

B：えーと、いないですね。

A：そうですか。わかりました。

## 3. はさみは、そこにあります

① 08-17

A：あのう、のりは、どこにありますか？

B：ここです。引(ひ)き出(だ)しの中(なか)にあります。はい、どうぞ。

A：あ、すみません。

② 08-18

A：すみません。ガムテープは、どこですか？

B：ガムテープ？　あそこです。箱(はこ)の中(なか)。

A：ああ、わかりました。

③ 08-19

A：あのう、すみません。FAX(ファックス)は、どこにありますか？

B：ああ、あそこ。コピー機(き)の横(よこ)。

A：あ、わかりました。ありがとうございます。

④ 08-20

A：はさみ、ありますか？

B：あ、そこにあります。机(つくえ)の上(うえ)です。

A：ああ、ありがとうございます。


©The Japan Foundation

⑤ 08-21

A：えーと、ごみ箱（ばこ）は……。

B：あ、そこそこ。

A：え？

B：机（つくえ）の下（した）。

A：あ、ありました。


©The Japan Foundation

# 漢字のことば

**1** 読んで、意味を確認しましょう。
ចូរអាន និងពិនិត្យមើលអត្ថន័យនៃអក្សរ កាន់ជិ ខាងក្រោមនេះ។

| | | | |
|---|---|---|---|
| 上（うえ） | 上 | 上 | 上 |
| 下（した） | 下 | 下 | 下 |
| 中（なか） | 中 | 中 | 中 |

**2** ＿＿＿の漢字に注意して読みましょう。
ចូរអានដោយយកចិត្តទុកដាក់ទៅលើអក្សរ កាន់ជិ ខាងក្នុង＿＿＿។

① Ａ：はさみは、どこにありますか？

　Ｂ：机の上です。

② のりは、引き出しの中にありますよ。

③ ごみ箱は、机の下です。

**3** 上の＿＿＿のことばを、キーボードやスマートフォンで入力しましょう。
សូមសាកល្បងវាយអក្សរ កាន់ជិ នៅខាងលើបន្ទាត់ចូលទូរស័ព្ទដៃ ឬកុំព្យូទ័រ។


©The Japan Foundation

# 文法ノート

## ❶ 【ទីកន្លែង 場所】で V-ます

ここで着替えます。
ប្ដូរសម្លៀកបំពាក់នៅទីនេះ។

- គេភ្ជាប់បរិវារសព្ទ で ពីក្រោយនាមទីកន្លែង ដើម្បីបង្ហាញថាគេធ្វើសកម្មភាពនៅកន្លែងនោះ ឧទាហរណ៍ ここで ។ ក្នុងមេរៀននេះ គេប្រើដើម្បីណែនាំកន្លែងការងារបណ្ដើរ ពន្យល់ពីការប្រើប្រាស់បន្ទប់នីមួយៗបណ្ដើរ។

- 助詞「で」は、「ここで」のように、場所を表す名詞のあとについて、動作の場所を示します。この課では、職場を案内しながら、何をする部屋か説明するときに使っています。

[例] ► ここは食堂です。ここで昼ご飯を食べます。
ឧទាហរណ៍ នេះជាបន្ទប់ញ៉ាំអាហារ។ គេញ៉ាំអាហារថ្ងៃត្រង់នៅទីនេះ។

## ❷ 【មនុស្ស 人】は【ទីកន្លែង 場所】に います

山田さんは、食堂にいます。
Yamada នៅក្នុងបន្ទប់ញ៉ាំអាហារ។

- នេះជាសំនួនពន្យល់អំពីទីតាំងនិងកន្លែងដែលមនុស្សណាម្នាក់ស្ថិតនៅ។ ក្នុងមេរៀននេះ គេប្រើពេលរកមនុស្សនិងប្រាប់ថាមនុស្សនោះកំពុងនៅឯណា។
- ពេលរៀបរាប់អំពីកន្លែងដែលមនុស្សស្ថិតនៅ គេប្រើកិរិយាសព្ទ いる ។ います ជាទម្រង់マスនៃកិរិយាសព្ទ いる ។
- សូមយកនាមមនុស្សមកធ្វើជាប្រធានហើយថែមបរិវាសព្ទ は ឧទាហរណ៍ 山田さんは។ ពេលបញ្ជាក់ពីទីកន្លែងដែលមនុស្សនោះនោះស្ថិតនៅសូមប្រើបរិវារសព្ទ に ឧទាហរណ៍ 食堂に ។
- ～にいますអាចនិយាយដោយងាយថា ～です។
- ពេលសួរថាតើមនុស្សស្ថិតនៅឯណា គេប្រើ どこ ហើយសួរថា ～は、どこにいますか? ឬ ～は、どこですか?។

- 人の居場所を説明するときの言い方です。この課では、職場で人を探したりどこにいるか教えたりするときに使っています。
- 人の居場所を述べるには、動詞「いる」を使います。「います」は「いる」のマス形です。
- 「山田さんは」のように人を話題（トピック）にして助詞「は」をつけます。その人がいる場所を、「食堂に」のように助詞「に」を使って示します。
- 「～にいます」は、簡単に「～です」で言い換えることができます。
- どこにいるかたずねるときは、疑問詞「どこ」を使って、「～は、どこにいますか?」または「～は、どこですか?」と質問します。

[例] ► A：田中さんは、どこにいますか?
ឧទាហរណ៍ តើ Tanaka នៅឯណា?
B：会議室です。
គាត់នៅក្នុងបន្ទប់ប្រជុំ។


©The Japan Foundation

A：山下(やました)さんは？
ចុះ Yamashita វិញ?
B：倉庫(そうこ)にいますよ。
គាត់នៅក្នុងឃ្លាំង។

❸

| ( 【 មនុស្ស 人(ひと)】は) | いません<br>いないです |
|---|---|

辻(つじ)さんは、いませんね。
Tsuji គាត់មិននៅទេ។

アマンダさん、いないですね。
Amanda គាត់មិននៅ។

- いません ជាទម្រង់បដិសេធរបស់ います ។
- いないです មានន័យដូចគ្នានឹង いません ដែរ។ វាជាទម្រង់ដែលដាក់ です នៅពីក្រោយ いない ដែលជាទម្រង់បដិសេធរបស់កិរិយាសព្ទ いる។

- 「いません」は「います」の否定の形です。
- 「いないです」は、「いません」と同じ意味です。「いる」の否定形「いない」の後ろに、「です」がついた形です。

[例(れい)] ឧទាហរណ៍
► A：田中(たなか)さん、いますか？
តើ Tanaka នៅដែរឬទេ?
B：今、いません。たぶん、会議室(かいぎしつ)にいます。
ឥឡូវគាត់មិននៅទេ។ ប្រហែលនៅក្នុងបន្ទប់ប្រជុំ។

► A：アンさん、いますか？
តើអ្នកនាង An នៅដែរឬទេ?
B：いないですね。
មិននៅទេ។
A：どこにいますか？
តើគាត់នៅឯណា?
B：ちょっとわかりません。
សុំទោសខ្ញុំមិនដឹងទេ។


©The Japan Foundation

❹

| 【 អ្វីមួយ もの】は | ここ<br>そこ<br>あそこ | に あります |
|---|---|---|

はさみは、そこにあります。
កន្ត្រៃនៅទីនោះ។

- នេះជារបៀបនិយាយពន្យល់អំពីកន្លែងដែលវត្ថុណាមួយស្ថិតនៅ។ ក្នុងមេរៀននេះ គេប្រើពេលប្រាប់ពីទីតាំងរបស់សម្ភារៈការិយាល័យ និងបរិក្ខារនៅកន្លែងធ្វើការ។
- ដើម្បីរៀបរាប់ពីកន្លែងដែលវត្ថុមួយស្ថិតនៅ គេប្រើកិរិយាសព្ទ ある។ ありますជាទម្រង់マスរបស់ ある។
- សូមយកវត្ថុមកធ្វើជាប្រធានហើយដាក់បរិវារសព្ទ は ឧទាហរណ៍ はさみは។ គេបញ្ជាក់ពីទីតាំងដែលវត្ថុមួយស្ថិតនៅដោយប្រើបរិវារសព្ទ に ឧទាហរណ៍ そこに ។
- សព្វនាមចង្អុលមាន៣គឺ ここ, そこ និង あそこ។ របៀបប្រើរបស់វាគឺអាស្រ័យលើទីតាំងរវាងអ្នកនិយាយនិងអ្នកស្តាប់។

  ① ここ ប្រើសម្រាប់ចង្អុលពីទីកន្លែងដែលនៅជិតអ្នកនិយាយ។
  ② そこ ប្រើសម្រាប់ចង្អុលពីទីកន្លែងដែលនៅជិតអ្នកស្តាប់។
  ③ あそこ ប្រើសម្រាប់ចង្អុលទីកន្លែងដែលនៅឆ្ងាយពីអ្នកនិយាយនិងអ្នកស្តាប់។

- ～にありますអាចនិយាយម្យ៉ាងទៀតដោយងាយបានថា～です។
- ពេលសួរថាតើស្ថិតនៅឯណា គេប្រើពាក្យ どこដោយសួរថា ～は、どこにありますか？ ឬ ～は、どこですか？។

- ものがある場所を説明するときの言い方です。この課では、職場で文房具や備品などがどこにあるか教えるときに使っています。
- ものがある場所を述べるには、動詞「ある」を使います。「あります」は「ある」のマス形です。
- 「はさみは」のように、ものを話題（トピック）にして助詞「は」をつけます。ものがある場所を、「そこに」のように助詞「に」を使って示します。
- 場所を示す指示詞には、「ここ」「そこ」「あそこ」の３種類があります。使い分けは、話し手と聞き手の位置関係によって決まります。
  ①「ここ」は、話し手の近くの場所を指すときに使います。
  ②「そこ」は、聞き手の近くの場所を指すときに使います。
  ③「あそこ」は、話し手からも聞き手からも離れた場所を指すときに使います。
- 「～にあります」は、簡単に「～です」で言い換えることができます。
- どこにあるかをたずねるときは、疑問詞「どこ」を使って、「～は、どこにありますか?」または「～は、どこですか?」と質問します。





©The Japan Foundation

[例(れい)] ► A：すみません。のり、ありますか?
ឧទាហរណ៍ សុំទោស។ មានកាវដែរឬទេ?
B ：ここにあります。
នៅទីនេះ។
► A：コピー機(き)は、どこにありますか?
តើម៉ាស៊ីនថតចម្លងនៅឯណា?
B：あそこです。
នៅខាងនោះ។

## ❺ Nの【 ទីតាំង 位置(いち)】に あります

引(ひ)き出(だ)しの中(なか)にあります。
នៅក្នុងថតតុ។

- សំនួននេះប្រើដើម្បីពន្យល់លម្អិតពីទីតាំងរបស់អ្វីមួយ។ នៅក្នុងមេរៀននេះ គេប្រើដើម្បីប្រាប់ពីទីតាំងសម្ភារៈការិយាល័យនិងបរិក្ខារជាដើម នៅកន្លែងការងារ។
-សូមប្រើវត្ថុណាមួយជាគោលដើម្បីពន្យល់ទីតាំង ដោយប្រើពាក្យដូចជា ～の上(うえ)/ 中(なか)/ 下(した) ជាដើម។

- 場所をくわしく説明するときの言い方です。この課では、職場の文房具や備品などの場所を教えるときに使っています。
- 基準になるものを使って、「～の上／中／下」のように位置を説明します。

[例(れい)] ► A：FAX(ファックス)は、どこにありますか。
ឧទាហរណ៍ តើទូរសារនៅឯណា?
B：あそこです。コピー機(き)の横(よこ)です。
នៅខាងនោះ។ នៅក្បែរម៉ាស៊ីនថតចម្លង។
► A：ごみ箱(ばこ)、ありますか。
តើមានធុងសំរាមទេ?
B：そこです。机(つくえ)の下(した)にあります。
នៅទីនោះ។ នៅក្រោមតុ។


©The Japan Foundation

### ◆ あります・います

កិរិយាសព្ទបង្ហាញពីវត្តមាន មាន あります (ある) និង います (いる)។ あります ប្រើជាមួយនាមដែលមិនធ្វើចលនាដូចជាកន្លែងការងារ ហើយ います ប្រើជាមួយនាមដែលមានជីវិតដូចជាមនុស្សនិងសត្វ។

存在を表す動詞には「あります（ある）」と「います（いる）」があります。「あります」は職場の備品など動かないものに、「います」は人や動物など、動いているものに使います。

| | あります（ある） | います（いる） |
|---|---|---|
| ពន្យល់ពីវត្តមានមនុស្ស/របស់អ្វីមួយ។<br>何があるか説明する | 【place 場所(ばしょ)】に<br>【something もの】があります<br>ここに冷蔵庫(れいぞうこ)があります。<br>នៅទីនេះមានទូទឹកកក។ | 【place 場所(ばしょ)】に<br>【person / animal 人(ひと)／動物(どうぶつ)】がいます<br>あそこに猫(ねこ)がいます。<br>នៅទីនោះមានឆ្មា។ |
| សួរពីទីតាំងមនុស្សឬរបស់អ្វីមួយ។<br>どこにあるか聞く | 【something もの】は<br>どこにありますか？<br>のりはどこにありますか？<br>តើកាវនៅឯណា? | 【person / animal 人(ひと)／動物(どうぶつ)】は<br>どこにいますか？<br>山田(やまだ)さんはどこにいますか？<br>តើ Yamada នៅឯណា? |
| ពន្យល់ពីទីតាំងមនុស្សឬរបស់អ្វីមួយ<br>どこにあるか説明する | 【something もの】は<br>【place 場所(ばしょ)】にあります<br>のりは引(ひ)き出(だ)しの中(なか)にあります。<br>កាវបិទនៅក្នុងថតតុ។ | 【person / animal 人(ひと)／動物(どうぶつ)】は<br>【place 場所(ばしょ)】にいます<br>山田(やまだ)さんは食堂(しょくどう)にいます。<br>Yamada នៅក្នុងបន្ទប់ញ៉ាំអាហារ។ |


©The Japan Foundation

日本の生活 TIPS

## 制服（せいふく） ឯកសណ្ឋាន



នៅក្នុងមេរៀននេះ មានលើកឧទាហរណ៍ពីការផ្លាស់សម្លៀកបំពាក់នៅបន្ទប់ផ្លាស់សម្លៀកបំពាក់នៅកន្លែងធ្វើការ។ នេះជាការផ្លាស់ប្តូរសម្លៀកបំពាក់ផ្ទាល់ខ្លួនមកឯកសណ្ឋានធ្វើការ។ នៅជប៉ុនមិនថាកន្លែងធ្វើការ ឬសាលារៀនទេ ភាគច្រើនមានឯកសណ្ឋាន។ ឯនៅរោងចក្រ ដើម្បីរក្សាសុវត្ថិភាពពេលធ្វើការកម្មករត្រូវស្លៀកឯកសណ្ឋានធ្វើការ ហើយក្រុមហ៊ុនអាចផ្តល់ឯកសណ្ឋានជូនដើម្បីជួយកាត់បន្ថយបន្ទុករបស់កម្មករ។ ការពាក់ឯកសណ្ឋាននៅកន្លែងធ្វើការអាចជួយឱ្យមើលដឹងថាជាអ្នកនៅក្រុមហ៊ុន ឬអ្នកមកពីក្រៅ ហើយគេក៏គិតថាវានឹងមានជួយបង្កើនស្មារតីសាមគ្គីភាពក្នុងក្រុមហ៊ុនដែរ។

ទោះបីជាគ្មានឯកសណ្ឋានក៏ដោយ អាស្រ័យលើប្រភេទអាជីវកម្ម ឬក្រុមហ៊ុនគេកំណត់ក៏អាចកំណត់យកសម្លៀកបំពាក់ណាមួយដែរ។ ឧទាហរណ៍ ធ្វើការនៅការិយាល័យហិរញ្ញវត្ថុគេអាចនឹងកំណត់ថាអ្នកត្រូវស្លៀកពាក់ដូចជាអាវធំពណ៌ខៀវចាស់ ឬពណ៌ប្រផេះចាស់ អាវសឺមីពណ៌ស ក្រវ៉ាត់កឆ្នូត ស្បែកជើងស្បែកពណ៌ខ្មៅជាដើម។ នៅក្នុងសង្គមជប៉ុន ពេលខ្លះគេទាមទារឱ្យស្លៀកសម្លៀកបំពាក់ដូចអ្នកដទៃជាជាងសម្លៀកបំពាក់ប្លែកខុសគេ។ កន្លែងធ្វើការនីមួយៗ ខុសៗ គ្នា ដូចនេះ ក្នុងករណីគ្មានឯកសណ្ឋានអ្នកគួរសួរទុកជាមុនពីសម្លៀកបំពាក់ដែលគួរពាក់នៅក្រុមហ៊ុន។

本文に、職場の更衣室で着替える場面が出てきましたが、これは私服から職場の制服に着替えることを意味しています。日本では、職場でも、学校でも、制服を取り入れているところが多くあります。工場などでは、働く際の安全確保のために作業服に着替えますが、作業服を会社から制服として支給することによって、労働者の負担を減らすことができます。また、職場の制服には会社の人と会社外の人をすぐ区別したり、会社内の一体感を高めたりという効果を期待している場合もあるようです。

制服がない場合も、業種や会社によっては一定の服装が期待されることもあります。例えば金融系のオフィスなら「紺か濃いグレーのスーツに白いシャツ、ストライプのネクタイ、黒い革靴」など、暗黙の了解として、同じような服装が期待されることもあります。日本社会では、個性的な服装よりも、ほかの人と同じような服装を求められる場合があります。職場によって異なりますので、制服がない場合は、会社での服装について、最初に聞いてみるといいでしょう。

## お茶（ちゃ） តែ

ក្នុងភាសាជប៉ុន ពេលនិយាយពាក្យថា お茶 អាចសំដៅលើតែបៃតង ហើយក៏អាចសំដៅលើតែធម្មតាដែរ។ គេឆុងតែបៃតងដោយប្រើប៉ាន់តែឬប្រើតែកញ្ចប់។ ភាគច្រើនគេផឹកជាតែក្តៅ ប៉ុន្តែថ្មីៗនេះ តែបៃតងត្រជាក់ច្រកដបប្លាស្ទិចក៏មានកាន់តែច្រើនឡើងដែរ។ តែមួយចំនួនផ្សេងទៀតដែលគេផឹកនៅជប៉ុនមានដូចខាងក្រោម។

日本語で「お茶」と言ったときは、緑茶を指すときと、広くお茶一般を指すときがあります。緑茶は、急須でいれたり、ティーバッグを使ったりします。温かいものを飲むことが多いですが、ペットボトルの冷たい緑茶も一般的になってきています。日本で飲まれるお茶には、ほかにも以下のようなものがあります。



តែបៃតង　緑茶

◈ 紅茶（こうちゃ）　តែក្រហម (紅茶, Koocha)

ជាតែប្រភេទផ្អាប់ទុកដែលគេនិយមផឹកនៅបរទេស។ នៅជប៉ុនភាគច្រើនគេឆុងដោយប្រើតែកញ្ចប់ដាក់ត្រាំក្នុងទឹកក្តៅ។

海外でよく飲まれている発酵したお茶。日本では温かいお湯にティーバッグの紅茶を入れて作られることが多い。


©The Japan Foundation

◈ 麦茶(むぎちゃ) **តែស្រូវបាលី** (麦茶, Mugicha)

ជាតែដែលធ្វើពីស្រូវបាលី។ គេច្រើនក្លាសេឱ្យ ហើយត្រជាក់ផឹកនៅរដូវក្ដៅ។ ហាងអាហារ ឬភោជនីយដ្ឋានខ្លះផ្ដល់ជូនតែស្រូវបាលីជំនួសទឹកធម្មតាដោយមិនគិតថ្លៃ។

大麦から作られたお茶で、特に夏、冷やして飲まれることが多い。飲食店では、水の代わりに麦茶を無料で出す店もある。



តែស្រូវបាលី
麦茶

◈ 抹茶(まっちゃ) **តែបៃតង** (抹茶, Matcha)

ធ្វើឡើងដោយយកស្លឹកតែទៅកិនឱ្យក្លាយជាម្សៅម៉ត់ ហើយត្រូវបានប្រើក្នុងពិធីឆុងតែរបៀបជប៉ុន។ គេមិនត្រឹមតែយក *Matcha* មកផឹកជាតែប៉ុណ្ណោះទេ គេក៏យកទៅប្រើជាគ្រឿងផ្សំក្នុងបង្អែមដូចជា នំខេក សូកូឡា និងការ៉េមជាដើម។

お茶の葉を粉にしたもので、茶道で使われるお茶。抹茶はお茶として飲むだけではなく、ケーキやチョコレート、アイスクリームなど、お菓子の材料としても人気がある。



Powdered green tea
抹茶

◈ ウーロン茶(ちゃ) **តែអ៊ូឡុង** (ウーロン茶ちゃ, Uroncha)

មានដើមកំណើតពីប្រទេសចិន។ គេផលិតដោយផ្អាប់ទុកពាក់កណ្ដាលមានពណ៌ត្នោត ហើយមានរសជាតិចត់ខុសគេ។

中国を原産とする、半分発酵させたお茶。茶色で独特の渋みがある。

ក្រៅពីនេះគេលាយតែប៉ុន្មានប្រភេទចូលគ្នាដើម្បីបង្កើតបានជាផលិតផលដែលលក់ក្នុងដបប្លាស្ទិចដូចជា 爽健美茶 (*Sokenbicha*) និង 十六茶(*Jurokucha*)។

ចំណុចពិសេសរបស់តែលក់ជាដបប្លាស្ទិចរបស់ជប៉ុនគឺមិនផ្អែមទេ ដោយសារគេមិនដាក់ស្ករចូលលើកលែងតែក្រហម។ វាត្រូវជាមួយនឹងអាហារដូចជាបាយ (*Onigiri*) និងបាយប្រអប់ (*Obento*)។

このほか、何種類かのお茶をブレンドした「爽健美茶」「十六茶」などの商品もあり、ペットボトルとして売られています。

日本のペットボトルのお茶は、紅茶以外は普通砂糖が入っていないので、甘くないことが特徴です。おにぎりやお弁当などを食べるときにいっしょに飲むと、よく合います。




## ▶ お茶(ちゃ)のいれ方(かた) របៀបឆុងតែ

ពេលឆុងតែបៃតងក្ដៅដោយប្រើប៉ាន់តែគេឆុងដូចខាងក្រោម។

急須で温かい緑茶をいれるときは、次のような方法でいれます。

1.


ចាក់ទឹកក្ដៅចូលពែងតែ។

湯飲みにお湯を入れます。

2.


ដាក់ស្លឹកតែចូលប៉ាន់។

急須にお茶の葉を入れます。

3.


ចាក់ទឹកក្ដៅពីពែងតែចូលប៉ាន់តែ។

急須に、湯飲みからお湯を移します。

4.


រង់ចាំមួយសន្ទុះរហូតដល់ស្លឹកតែរីក។

お茶の葉が開くまで、しばらく待ちます。

5.


ចាក់ទឹកតែពីប៉ាន់តែចូលពែងតែ។

急須から湯飲みにお茶を入れます。

You can also skip steps 1 and 3, and pour the hot water directly into the teapot.

なお、１と３を省略して、急須に直接お湯を注ぐ場合もあります。


©The Japan Foundation

## FAX（ファックス） (ទូរសារ)



FAX (ទូរសារ) ជាម៉ាស៊ីនដែលបំលែងរូបភាពពីអ្នកផ្ញើទៅជាទិន្នន័យបញ្ជូនតាមរយៈខ្សែរទូរស័ព្ទ រួចព្រីនចេញជាក្រដាសនៅខាងអ្នកទទួល។ គេប្រើទូរសារទូទាំងពិភពលោករហូតដល់ទសវត្សឆ្នាំ១៩៩០។ គេលែងប្រើបន្តិចម្តងៗ ដោយសារមានការរីកចម្រើនផ្នែកអ៊ីនធឺណេត។

ទោះជាយ៉ាងណា នៅជប៉ុនគេនៅប្រើតែទូរសារនៅឡើយ។ គេច្រើនប្រើពេលផ្ញើឯកសារទាក់ទងនឹងស្ថាប័នរដ្ឋ ឬប្រើសម្រាប់ទំនាក់ទំនង និងជូនដំណឹងទាក់ទងនឹងប្រព័ន្ធផ្សព្វផ្សាយ។ មូលហេតុដែលនៅជប៉ុនគេនៅប្រើទូរសារនៅឡើយ គឺដោយសារអ្នកខ្លះគិតថាការផ្ញើរូបភាពដែលមានវាយត្រា ឬឯកសារសរសេរដៃតាមទូរសារអាចទុកចិត្តបានជាងផ្ញើតាមអ៊ីមែល។ នីតិវិធីនៅស្ថាប័នរដ្ឋខ្លះ ទោះជាសម័យបច្ចុប្បន្ននេះក៏ដោយក៏នៅមិនទទួលឯកសារតាមអ៊ីមែលដែរ លុះត្រាតែផ្ញើតាមទូរសារទើបទទួល។

FAX（ファクシミリ）は、送信元の画像をデータに変換して電話回線を通じて送り、送信先で紙に印刷することができる機械です。1990年代までは、世界で使われていましたが、インターネットの普及とともに、だんだん使われなくなってきました。

しかし、日本ではいまだに FAX は現役です。特に、役所関係の文書のやりとりや、マスコミ関係の通知や連絡などに、FAX を使うことが少なくありません。日本で今も FAX が使われている理由としては、FAX はハンコの画像や手書きの書類がそのまま送れるので、インターネットのメールよりも信用できるから、という理由を挙げる人もいます。役所の手続きなどでは、今でも e メールでの連絡を認めず、FAX を送らなければ受け付けてもらえないこともあります。


©The Japan Foundation